# ស្ថានភាពអតិផរណានៅខែកក្កដា ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែកក្កដា មានការថយចុះ **0,៣%** ធៀបនឹងខែមុន ប៉ុន្តែកើនឡើង **២,៣%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្នុងខែកក្កដា ឆ្នាំ ២០១៨ នេះ សន្ទស្សន៍ថ្លៃទំនិញភាគច្រើននៅតែបន្តកើនឡើងបើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ប៉ុន្តែមានកម្រិតទាបជាងអត្រាកំណើនក្នុងខែមិថុនាកន្លងទៅ ដោយសារកំណើនថមថយនៃសន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង, ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់, សម្លៀកបំពាក់ និងស្បែកជើង, ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត និងការដឹកជញ្ជូន។ តាមការសង្កេត សន្ទស្សន៍ថ្លៃទំនិញមួយចំនួនដែលមានការថមថយកំណើនគួរឱ្យកត់សម្គាល់ រួមមានដូចជា សន្ទស្សន៍ថ្លៃសាច់កើនឡើង ២% (កើនឡើង ២,៤% ក្នុងខែមិថុនា), ប្រេងសាំងធម្មតាកើន ៩,៤% (កើនឡើង ១២,២% ក្នុងខែមិថុនា), ម៉ាស៊ូតកើន ៦,៥% (កើនឡើង ៨,៦% ក្នុងខែមិថុនា), ហ្គាសកើន ៧,៧% (កើនឡើង ៩,៦% ក្នុងខែមិថុនា) និងសម្លៀកបំពាក់កើន ២% (កើនឡើង ៣,២% ក្នុងខែមិថុនា)។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **-0,៣** | **+២,៣** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | -0,៤ | +២,៣ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | -0,៧ | +១,0 |
| ៣-សម្លៀកបំពាក់និងស្បែកជើង | -0,៣ | +១,៦ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | -0,២ | +0,៩ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | -0,៣ | +0,២ |
| ៦-សុខាភិបាល | 0,0 | +១,២ |
| ៧-ការដឹកជញ្ជូន | -១,១ | +៣,៧ |
| ៨-គមនាគមន៍ | -0,១ | -0,៤ |
| ៩-ការកំសាន្ត និងវប្បធម៌ | -0,១ | -0,៩ |
| ១0-ការសិក្សា | +0,៤ | 0,0 |
| ១១-ភោជនីយដ្ឋាន | +១,២ | +៥,៦ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +0,៣ | +៣,៧ |

| តារាង ១ ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | | | ២០១៨ | | |
| | ឧសភា | មិថុនា | កក្កដា | ឧសភា | មិថុនា | កក្កដា |
| អង្ករ | +០,៣ | +០,៣ | ០,០ | +២,៦ | +២,៣ | +២,១ |
| សាច់គោ | +០,៥ | -០,៥ | -០,៣ | +៤,២ | +៤,០ | +៣,៤ |
| សាច់មាន់ | +០,៣ | +០,៣ | +០,១ | +៣,១ | +២,៧ | +២,៤ |
| សាច់ទា | -០,១ | -០,៤ | +០,៥ | +២,៤ | +២,៤ | +២,០ |
| សាច់ជ្រូក | -០,១ | +០,២ | -០,២ | +១,៣ | +១,៦ | +១,៣ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +០,៨ | +០,៤ | -០,៨ | +៥,៣ | +៤,៩ | +៣,៨ |
| ក្នុងនោះត្រីស្រស់ | +១,០ | +០,៤ | -១,១ | +៥,៦ | +៤,៩ | +៣,៦ |
| ផ្លែឈើ | -០,៧ | +០,២ | -០,៩ | +៣,៨ | +៣,៦ | +១,៨ |
| ផ្លែឈើស្រស់ | -០,៨ | +០,២ | -១,២ | +៣,៥ | +៣,៧ | +១,៣ |
| បន្លែ | +០,៨ | +០,១ | -០,៦ | +៣,១ | +៥,១ | +២,៨ |
| បន្លែជាស្លឹក | +០,៩ | +០,៨ | +០,៥ | +៤,៣ | +៧,៤ | +៥,៣ |
| បន្លែជាផ្លែ | +០,៤ | -០,៦ | -១,៨ | +៣,១ | +៥,៣ | +២,២ |

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៧ | | | | ២០១៨ | | | |
| | មេសា | ឧសភា | មិថុនា | កក្កដា | មេសា | ឧសភា | មិថុនា | កក្កដា |
| ប្រទេសកម្ពុជា | 3.2 | 2.5 | 2.3 | 2.3 | 2.4 | 2.9 | 2.9 | 2.3 |
| ប្រទេសវៀតណាម | 4.3 | 3.2 | 2.5 | 2.5 | 2.8 | 3.9 | 4.7 | 4.5 |
| ប្រទេសថៃ | 0.4 | 0.0 | -0.1 | 0.2 | 1.07 | 1.49 | 1.38 | 1.5 |
| ប្រទេសម៉ាឡេស៊ី | 4.4 | 3.9 | 3.6 | 3.2 | 1.4 | 1.8 | 0.8 | 0.9 |
| ប្រទេសឥណ្ឌូនេស៊ី | 4.2 | 4.3 | 4.4 | 3.9 | 3.4 | 3.2 | 3.1 | 3.2 |
| ប្រទេសហ្វីលីពីន | 3.2 | 2.9 | 2.5 | 2.4 | 4.5 | 4.6 | 5.2 | 5.7 |
| ប្រទេសចិន | 1.2 | 1.5 | 1.5 | 1.4 | 1.8 | 1.8 | 1.9 | 2.1 |
| ប្រទេសកូរ៉េខាងត្បូង | 1.9 | 2.0 | 1.9 | 2.2 | 1.6 | 1.5 | 1.5 | 1.5 |
| ប្រទេសជប៉ុន | 0.4 | 0.4 | 0.4 | 0.4 | 0.6 | 0.7 | 0.7 | 0.9 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*